**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីជូនព័ត៌មាន

ពាក់ព័ន្ធនឹងសភាពការណ៍វិវឌ្ឍនៃជំងឺឆ្លងផ្លូវដង្ហើមកូរ៉ូណា នៅសាធារណរដ្ឋប្រជាមានិតចិន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមជម្រាបជូនសាធារណជន មេត្តាជ្រាបដូចខាងក្រោម៖

- កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានតាមដានដោយយកចិត្តទុកដាក់ខ្ពស់បំផុត ចំពោះស្ថានការណ៍វិវត្តនៃការរាលដាលជំងឺឆ្លងផ្លូវដង្ហើមកូរ៉ូណានេះ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងបណ្តាស្ថានតំណាងរបស់កម្ពុជា នៅសាធារណរដ្ឋប្រជាមានិតចិន បានធ្វើការទាក់ទងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ និងក្រសួងការបរទេសចិន ដើម្បីតាមដានបច្ចុប្បន្នភាពនៃសុខុមាលភាពរបស់ពលរដ្ឋខ្មែរ ជាពិសេសនិស្សិតខ្មែរដែលកំពុងសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ។
- ទន្ទឹមនឹងការផ្តល់ទំនុកចិត្តលើចំណាត់ការប្រកបដោយការទទួលខុសត្រូវរបស់អាជ្ញាធរចិន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានណែនាំឱ្យស្ថានតំណាងព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ទាក់ទងជាប្រចាំជាមួយនឹងអាជ្ញាធរពាក់ព័ន្ធរបស់ចិន ដើម្បីផ្ញើជូននិស្សិតខ្មែរនូវគ្រឿងបរិក្ខារអនាម័យចាំបាច់នានា។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក៏បានទទួលការបញ្ជាក់ប្រកបដោយភាពកក់ក្តៅថា សាកលវិទ្យាល័យចិនបានឧបត្ថម្ភស្បៀងនិងសម្ភារៈចាំបាច់នានាដល់និស្សិត ហើយបានសំណូមពរអោយអនុវត្ត និងគោរពតាមវិធានការបង្ការ និងទប់ស្កាត់ដែលអាជ្ញាធរចិនបានដាក់ចេញ ដើម្បីធានានូវសុវត្ថិភាព និងសុខភាពផ្ទាល់ខ្លួនផង និងសាធារណៈផង។
- មកដល់បច្ចុប្បន្ននេះ ពុំមានករណីឆ្លងមេរោគនេះលើពលរដ្ឋខ្មែរទេ។
- ក្នុងស្មារតីយកចិត្តទុកដាក់ជួយឧបត្ថម្ភ និងតាមដានសុខុមាលភាពរបស់ពលរដ្ឋយើង ជាពិសេសនិស្សិតខ្មែរដែលកំពុងស្នាក់នៅ និងសិក្សានៅប្រទេសចិន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងស្ថានតំណាងកម្ពុជា នៅសាធារណរដ្ឋប្រជាមានិតចិន បានបង្កើតបណ្តាញ WeChat ជាមួយនិស្សិតខ្មែរនៅតាមតំបន់នានា នៅប្រទេសចិន ដើម្បីសម្រួលដល់ទំនាក់ទំនង និងការផ្តល់ព័ត៌មានបានទាន់ពេលវេលា។ ទន្ទឹមនឹងនេះ ក្រសួងការបរទេស

អាសយដ្ឋាន៖ លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

និងសហប្រតិបត្តិការអន្តរជាតិក៏បានរៀបចំជាប្រព័ន្ធទូរស័ព្ទសំរាប់មាតាបិតាអាណាព្យាបាល និស្សិតដែលកំពុងស្នាក់អាស្រ័យនៅប្រទេសចិន ដែលចង់បានព័ត៌មានបន្ថែមឬមានចំងល់ទាក់ទងនឹងសុវត្ថិភាព និងសុខភាពនិស្សិត តាមលេខទំនាក់ទំនង ដូចខាងក្រោម៖

- លោក ជ័យ រដ្ឋា 077 575 807
- លោក យស សុខេមរិន 012 445 959
- លោក ហាន ឧសភា 089 216 599

ថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២០